**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៩៣៧.០២២.០០៣ ប្រកាសព័ត៌មាន

*ថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយ ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ សម្រាប់មន្ត្រីត្រួតពិនិត្យនិងបុគ្គលរាយការណ៍ក្នុងវិស័យធនាគារ

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់មេត្តាជ្រាបថា ដោយមានកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង-ស្ថាប័នរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ ធនាគារជាតិនៃកម្ពុជាបានរៀបចំវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ (ZOOM) លើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យសម្រាប់មន្ត្រីត្រួតពិនិត្យនិងបុគ្គលរាយការណ៍ក្នុងវិស័យធនាគារ ដូចខាងក្រោម៖

**១. សិក្ខាសាលាផ្សព្វផ្សាយដល់មន្ត្រីត្រួតពិនិត្យត្រូវបានរៀបចំឡើងចំនួន ៣ លើក៖**

- លើកទី១ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ចូលរួមដោយនាយកដ្ឋានត្រួតពិនិត្យ ១ នៃអគ្គនាយកដ្ឋានត្រួតពិនិត្យដែលទទួលខុសត្រូវត្រួតពិនិត្យធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីមន្ត្រីត្រួតពិនិត្យទាំងអស់ចំនួន ៣០ រូប។
- លើកទី២ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ ចូលរួមដោយនាយកដ្ឋានត្រួតពិនិត្យ ២ នៃអគ្គនាយកដ្ឋានត្រួតពិនិត្យដែលទទួលខុសត្រូវត្រួតពិនិត្យធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ គ្រឹះស្ថានឥណទានជនបទ និងអាជីវកម្មប្តូរប្រាក់។ វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីមន្ត្រីត្រួតពិនិត្យទាំងអស់ចំនួន ៣២ រូប។
- លើកទី ៣ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ចូលរួមដោយនាយកដ្ឋានគោលនយោបាយ បទប្បញ្ញត្តិនិងវាយតម្លៃហានិភ័យ នាយកដ្ឋានគ្រប់គ្រងទិន្នន័យនិងវិភាគម៉ាក្រូ នៃអគ្គនាយកដ្ឋានត្រួតពិនិត្យ និងនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់នៃអគ្គនាយកដ្ឋាន



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

បច្ចេកទេស។ វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីមន្ត្រីត្រួតពិនិត្យទាំងអស់ចំនួន ៦០ រូប។

**២. សិក្ខាសាលាផ្សព្វផ្សាយដល់បុគ្គលរាយការណ៍ក្នុងវិស័យធនាគារត្រូវបានរៀបចំឡើងចំនួន ២ លើក៖**

- លើកទី១ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដែលមានការចូលរួមពីតំណាងធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ទាំងអស់ចំនួន ៨៥ រូប។
- លើកទី២ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ដែលមានការចូលរួមពីតំណាងធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ទាំងអស់ចំនួន ១០៣ រូប។

លើសពីនេះ ធនាគារជាតិនៃកម្ពុជាមានផែនការបណ្តុះបណ្តាលដល់បុគ្គលរាយការណ៍តូចៗផ្សេងទៀតរួមមាន គ្រឹះស្ថានឥណទានជនបទ អាជីវកម្មប្តូរប្រាក់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ នេះ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**
www.nbc.org.kh, www.facebook.com/nationalbankofcambodiaofficial, www.twitter.com/nbccambodia, www.instagram.com/nationalbankofcambodia, www.linkedin.com/company/national-bank-of-cambodia, www.youtube.com/nationalbankofcambodia